ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ
THE STUDENT MOVEMENT FOR DEMOCRACY

លេខ៖ ០០១១/២១ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

# សេចក្តីថ្លែងការណ៍

## ខួប៥ឆ្នាំនៃឃាតកម្មលោកបណ្ឌិត កែម ឡី

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** ពិនិត្យឃើញថា ករណីឃាតកម្មលោកបណ្ឌិត **កែម ឡី** កាលពី៥ឆ្នាំមុន នៅពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ មិនទាន់ត្រូវបានវែកមុខចាប់ខ្លួនឃាតកពិត និងអ្នកពាក់ព័ន្ធ យកទៅផ្តន្ទាទោស តាមផ្លូវច្បាប់នៅឡើយ។ ដោយសិក្សាលើព៌មានច្រើនប្រភព យើងសន្និដ្ឋានថា លោក **អឿត អាង** (ឬ **ជួប សម្លាប់**) គឺជាឃាតកសិប្បនិម្មិត។ ការពិតលោក **អឿត អាង** ក៏ជាជនរងគ្រោះ ដែលអ្នករៀបចំឃាតកម្ម ប្រើប្រាស់តែប៉ុណ្ណោះ។

**ចលនានិស្សិតដើម្បីលទ្ធិប្រធិបតេយ្យ** នៅតែបន្តទាមទារឲ្យតុលាការកម្ពុជា បង្ហាញរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួនច្បាស់លាស់ និងជាសាធារណៈ ទៅតាមអង្គហេតុនៃព្រឹត្តិការណ៍ធ្វើឃាតសម្លាប់លោកបណ្ឌិត **កែម ឡី** ដើម្បីជម្រះមន្ទិលសង្ស័យពីមជ្ឈដ្ឋាននានា ទាំងជាតិ និងអន្តរជាតិ ដែលចោទប្រកាន់អំពីការពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់ក្នុងជួរអាជ្ញាធររដ្ឋាភិបាល។ ក្នុងគោលដៅស្តារមុខមាត់ប្រព័ន្ធយុត្តិធម៌ និងកិត្តិយសរដ្ឋាភិបាលកម្ពុជា តុលាការត្រូវមានសេចក្តីក្លាហានបង្ហាញអង្គចងចាំនៃប្រព័ន្ធកាមេរ៉ាសុវត្ថិភាព នៅស្ដាម៉ាត(**Star Mart**) ស្តុបបូគោ (ស្តុបកែមឡី) ខណ្ឌចំការមន រាជធានីភ្នំពេញ រយៈពេល ២៤ម៉ោងពេញ ក្នុងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ ចំថ្ងៃឃាតកម្មលោក បណ្ឌិត **កែម ឡី**។

តុលាការកម្ពុជានៅជំពាក់ពលរដ្ឋខ្មែរទូទៅ និងជាពិសេសក្រុមគ្រួសារជនរងគ្រោះ ដែលកំពុងទ្រហោយំចង់បានយុត្តិធម៌ខ្លាំងណាស់។ ដោយហេតុនេះ យើងខ្ញុំក៏សូមទាមទារយ៉ាងទទូចឲ្យតុលាការកម្ពុជា បើកការស៊ើបអង្កេតឡើងវិញលើសំណុំរឿងឃាតកម្ម ឧត្តមសេនីយ៍ **ហូ សុខ**, ឧត្តមសេនីយ៍ **ចៅ សម្បត្តិ**, ឧត្តមសេនីយ៍ **លី សេងហុង**, ឧត្តមសេនីយ៍ **ក្រូច យឿម**, ឧត្តមសេនីយ៍ **ជា ឫទ្ធីឈុត**, ឧត្តមសេនីយ៍ **ម៉ែន ប៊ុនថន**, ព្រះសង្ឃ **សំ ប៊ុនធឿន**, ទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា **ឱម រដ្ឋសាឌី**, មេដឹកនាំសេរីសហជីពកម្មករ **ជា វិជ្ជា**, អ្នកដឹកនាំសហជីព **រស់ សុវណ្ណារេត**, អ្នកដឹកនាំសហជីព **ហ៊ី វុទ្ធី**, សកម្មជនព្រៃឈើ **ឈុត វុទ្ធី**, អ្នកកាសែត **ឃឹម សំបូរ**, អ្នកកាសែត **ធន់ ប៊ុនលី**, អ្នកកាសែត **ជួ ជិតថារិទ្ធ**, តារាភាពយន្ត **ពិសិដ្ឋ ពីលិកា**, និងជនរងគ្រោះផ្សេងៗទៀត ដូចជាករណីតារាភាពយន្ត **តាត ម៉ារ៉ាំរីណា** និងតារាចម្រៀង **ទូច ស៊ុននិច** ដែលកំពុងរស់ក្នុងស្ថានភាពពិការភាពដ៏គួរឲ្យសង្វេកបំផុត។ល។

យើងខ្ញុំយល់ឃើញថា មានតែយុត្តិធម៌ទេ ដែលជាបង្អែកនៃស្ថិរភាពសង្គមនិងសន្តិភាព។ ដូច្នេះ ដើម្បីឆ្លុះបញ្ចាំងអំពីការអះអាងរបស់រដ្ឋាភិបាល ដែលថា កម្ពុជាមានសន្តិភាពនោះ ទាល់តែ**រដ្ឋាភិបាលដោះលែងអ្នកទោសមនសិការបច្ចុប្បន្ន ឲ្យឃើញយុត្តិធម៌ជាក់ស្តែង**។

**ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ** សូមអំពាវនាវដល់តុលាការ និងអាជ្ញាធររដ្ឋាភិបាលកម្ពុជា ត្រូវស្តាប់សំឡេងពលរដ្ឋជាម្ចាស់ប្រទេស និងបំពេញកាតព្វកិច្ចរបស់ខ្លួនតាមច្បាប់ ឲ្យឆ្លើយតបនឹងសេចក្តីត្រូវការរបស់ពលរដ្ឋខ្មែរ ជាពិសេសក្រុមគ្រួសារជនរងគ្រោះដែលកំពុងទទួចរកយុត្តិធម៌យ៉ាងពិតប្រាកដ។

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**

2402 24TH ST SE, WASHINGTON, DC 20020 | TEL: (202) 430-5503 | EMAIL: INFO@SMD2.NET | WWW.SMD2.NET